សេចក្ដីសង្ខេបគោលនយោបាយ

# ការវិភាជន៍ថវិកាថ្នាក់ជាតិ និងការចូលរួមរបស់ប្រជាពលរដ្ឋជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ

ស្កែនដើម្បីទទួលបានឯកសារ

ឯកសារបកប្រែ

## ១.សារតា

រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តចំពោះការអនុវត្តកំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) ដែលតម្រង់ទិសដោយក្របខណ្ឌយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល សម្រាប់កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ កម្មវិធីអភិវឌ្ឍជាតិ និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធចាប់តាំងពីឆ្នាំ២០០៥។ ទិសដៅនៃកំណែទម្រង់ក៏ត្រូវបានចាត់ទុកថាជាគន្លឹះនៃកំណែទម្រង់អភិបាលកិច្ចតាមរយៈការអនុវត្តគោលការណ៍ណែនាំសំខាន់ៗ នៃអភិបាលកិច្ចក្នុងយុទ្ធសាស្ត្រចតុកោណ។ ដំណើរការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមជាមួយនឹងកំណែទម្រង់រដ្ឋបាលសាធារណៈ និងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានគោលបំណងបង្កើតវប្បធម៌ប្រជាធិបតេយ្យនៅថ្នាក់មូលដ្ឋាន បង្កើនការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងកិច្ចការក្រុមប្រឹក្សាថ្នាក់ក្រោមជាតិ ដោយរំពឹងថាសេវាសាធារណៈនៅថ្នាក់ក្រោមជាតិមានតម្លាភាព គណនេយ្យភាព និងឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗនៅថ្នាក់ក្រោមជាតិ។

រាជរដ្ឋាភិបាលកម្ពុជា រួមជាមួយភាគីពាក់ព័ន្ធសំខាន់ៗ ដូចជា អង្គការសង្គមស៊ីវិល បានបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (NP-២, ២០២១-២០៣០) និងអនុវត្តន៍ផែនការរយៈពេល៥ឆ្នាំ (IP-៥, ២០២១-២០២៥) ជាមួយនឹងការប្ដេជ្ញាចិត្តក្នុងការលើកស្ទួយប្រទេសជាតិ ពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាបទៅជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ ។

អំឡុងពេលអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី១ (NP-1, ២០១០-២០១៩) មានបញ្ហាប្រឈមមួយចំនួនដែលបានកើតឡើងគួរឱ្យកត់សម្គាល់រួមមាន ការស្ទាក់ស្ទើររបស់ស្ថាប័នជាតិមួយចំនួន ក្នុងការផ្ទេរអំណាច មុខងារ និងធនធាន "មនុស្ស និងហិរញ្ញវត្ថុ" ទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់លើការចូលរួមរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តគណនេយ្យភាពសង្គមក៏ដោយ ចំណេះដឹងរបស់ប្រជាពលរដ្ឋនៅមានកម្រិតអំពីសិទ្ធិរបស់ខ្លួន និងរបៀបទាមទាររដ្ឋបាលថ្នាក់ក្រោមជាតិឱ្យទទួលខុសត្រូវចំពោះពួកគេ ហើយធនធានហិរញ្ញវត្ថុដែលផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានការកើនឡើង ប៉ុន្តែចំនួននេះនៅមិនទាន់គ្រប់គ្រាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការបំពេញការទទួលខុសត្រូវរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបាន។ ការទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ (ឧទាហរណ៍ ព័ត៌មានអំពីថវិកា និងការសម្រេចចិត្ត) ក៏ជាបញ្ហាប្រឈមនៅទូទាំងរដ្ឋបាលថ្នាក់ក្រោមជាតិផងដែរ។

ការបំពេញតួនាទីបន្ថែមរបស់អង្គការសង្គមស៊ីវិល (CSOs) ក្នុងការចូលរួមយ៉ាងសកម្ម ក្នុងដំណើរការកំណែទម្រង់ត្រូវបានលើកឡើងនៅកម្មវិធីជាតិដំណាក់កាលទី២។ ការចូលរួមរបស់ពួកគេរួមទាំងការបំពេញតួនាទីជាស្ពានរវាងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ ដែលជាកត្តាជំរុញដល់ការអនុវត្តកំណែទម្រង់ទូទាំងប្រទេស។ លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) បានបង្ហាញការប្ដេជ្ញាចិត្តយ៉ាងមុតមាំក្នុងការសម្របសម្រួល និងការអនុវត្តការសន្យានានាក្នុងការអនុវត្តកម្មវិធីជាតិដំណាក់កាលទី២ និងផែនការរយៈពេល៥ឆ្នាំ រួមបញ្ចូលទាំងការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការអនុវត្តគម្រោងគណនេយ្យភាពសង្គម។ រាជរដ្ឋាភិបាលកម្ពុជាបានប្ដេជ្ញាចិត្តថានឹងខិតខំប្រឹងប្រែងបន្ថែមទៀត តាមរយៈការអញ្ជើញឱ្យមានការ

ចូលរួមជាផ្លូវការ ឬមិនផ្លូវការក្តីរបស់អង្គការសង្គមស៊ីវិល ក្នុងការធ្វើការសម្រេចចិត្តនៅក្នុងគោលនយោបាយផ្សេងៗ ជាពិសេសការអភិវឌ្ឍថវិកាជាតិ និងការបែងចែកថវិកាទៅថ្នាក់ក្រោមជាតិ ដោយសារខណៈពេលនេះ មិនទាន់មានការអនុញ្ញាតណាមួយជាផ្លូវការសម្រាប់អង្គការសង្គមស៊ីវិល ឬតំណាងសាធារណៈជន ក្នុងការផ្តល់ធាតុចូលទៅក្នុងគោលនយោបាយជាតិ ទោះបីកម្មវិធីជាតិ ដំណាក់កាលទី២ (NP-២) បានបញ្ជាក់យ៉ាងច្បាស់ថា "គ.ជ.អ.ប" នឹងបន្តពង្រឹងយន្តការដែលធានាបរិយាកាសការងារជាវិជ្ជមានសម្រាប់អង្គការសង្គមស៊ីវិល ដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍគោលនយោបាយ[១] ដើម្បីរួមចំណែកដល់ការពង្រឹងការគ្រប់គ្រងដំណើរការកែទម្រង់តាមបែបវិមជ្ឈការ និងវិសហមជ្ឈការ[២]។ លើសពីនេះ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ក៏បានទទួលស្គាល់ពីតួនាទីសំខាន់នៃការចូលរួមរបស់អង្គការសង្គមស៊ីវិល ក្នុងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិទទួលព័ត៌មានរបស់ប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាព័ត៌មានទាក់ទងនឹងការរៀបចំផែនការថវិកា និងដំណើរការ។

## ២. វិធីសាស្ត្រនៃការសិក្សា

ការពិនិត្យសិក្សាឡើងវិញនេះបានធ្វើឡើងដោយផ្អែកលើបទប្បញ្ញត្តិ កម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ឯកសារកម្មវិធីជាតិ របាយការណ៍សិក្សាស្រាវជ្រាវ និងភស្តុតាងស្តីពីថវិកា និងការចំណាយថ្នាក់ក្រោមជាតិ ដែលបង្ហាញជាសាធារណៈពីស្ថាប័នរាជរដ្ឋាភិបាល និងឯកសារសង្ខេបគោលនយោបាយនានាដែលពាក់ព័ន្ធ។

ក្រុមការងារអង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (សម្ព័ន្ធភាព CPDD) បានធ្វើការស្ទង់មតិតាមប្រព័ន្ធអ៊ីនធឺណិត ជាមួយអង្គការសមាជិក ក៏ដូចជាការពិគ្រោះយោបល់ជាមួយសមាជិកសម្ព័ន្ធភាព CPDD មួយចំនួន ដើម្បីស្វែងយល់ពីបទពិសោធន៍ស្តីពីការចូលរួមរបស់ប្រជាពលរដ្ឋនៅថ្នាក់ក្រោមជាតិ និងមតិកែលម្អ ក្នុងការរៀបចំផែនការ និងថវិកា សកម្មភាព ស្ថានភាពនៃការបើកចំហព័ត៌មានជាសាធារណៈ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងការទទួលព័ត៌មានរបស់ប្រជាពលរដ្ឋ និងកំណត់នូវកិច្ចខិតខំប្រឹងប្រែងលើសកម្មភាពរបស់ប្រជាពលរដ្ឋ ក្នុងការតាមដានការប្រើប្រាស់ថវិកាសាធារណៈ។

អ្នកពាក់ព័ន្ធសំខាន់ៗក៏ត្រូវបានជ្រើសរើសផ្តល់ព័ត៌មានផងដែរ។ ការពិនិត្យអក្សរកម្ម ការស្ទង់មតិ និងការចុះសម្ភាសន៍ផ្ទាល់ដោយផ្តោតលើបទពិសោធន៍ជាក់ស្តែង និងបញ្ហាប្រឈមនានាទាក់ទងនឹងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការធ្វើផែនការ និងដំណើរការថវិកា លទ្ធភាពទទួលបានព័ត៌មាន និងការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងការអភិវឌ្ឍ និងការបែងចែកថវិកាជាតិ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ និងស្វែងយល់ពីការខិតខំប្រឹងប្រែង ដោះស្រាយបញ្ហាអន្តរវិស័យ មានដូចជាថវិកាឆ្លើយតបយេនឌ័រ សមភាពសង្គម និងបរិយាបន្ន។

## ៣. លទ្ធផលនៃការសិក្សា និងអនុសាសន៍

### ៣.១. ថវិកាថ្នាក់ក្រោមជាតិ និងការវិភាជន៍

កំណែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរបស់ប្រទេសកម្ពុជាគឺជំរុញការធ្វើសម្រេចចិត្តក្នុងការផ្តល់សេវាឱ្យកាន់តែជិតប្រជាពលរដ្ឋ[៣] មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវការធនធាន "ថវិកា" បន្ថែម តួនាទី និងអំណាច។ ថវិកា តួនាទី និងអំណាចទាំងនោះត្រូវផ្ទេរពីថ្នាក់ជាតិ។ ក្នុងឆ្នាំទី៣ នៃកម្មវិធីជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិដំណាក់កាលទី២ (២០២១-២០៣០) ការវិភាជន៍ថវិកាពីថ្នាក់ជាតិ ទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់)[៤] ទោះបីជាការវិភាជន៍ថវិកាត្រូវបានកើនឡើងជារៀងរាល់ឆ្នាំពី១០.៦% នៅឆ្នាំ២០២១ ដល់ ១២.៣% ក្នុងឆ្នាំ២០២២ ដល់ ១២.៩% ក្នុងឆ្នាំ២០២៣ នៃថវិកាជាតិក៏ដោយ ចំនួនសរុបនៃថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនៅតែមានកម្រិតទាបនៅឡើយ បើធៀបទៅនឹងការចំណាយរបស់រដ្ឋាភិបាលថ្នាក់កណ្តាល។ រដ្ឋបាលស្រុក/ក្រុងកំពុងក្លាយជាចំណុចសំខាន់នៃការផ្តល់សេវា ដូចនេះ រដ្ឋបាលស្រុក/ក្រុងគួរតែមាន"ចំណែកសម្រាប់ចំណាយពី ៣០% - ៣៥% នៃការចំណាយសរុបរបស់រដ្ឋាភិបាល" នេះបើយោងតាមអនុសាសន៍ដែលធ្វើឡើងដោយក្រុមការងារថវិកា/ធនាគារអភិវឌ្ឍអាស៊ី (BWG/ADB)[៥] នៅក្នុងកម្មវិធីជាតិដំណាក់កាលទី២ (NP-២) បានទទួលស្គាល់ថា សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដែលត្រូវបានផ្ទេរពីថ្នាក់ជាតិ ហើយការអភិវឌ្ឍ និងការវិភាជន៍ថវិកា ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវតែអនុវត្តប្រកបដោយតម្លាភាព និងអាចព្យាករណ៍បាន ដែលអនុញ្ញាតឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្លើយតបកាន់តែប្រសើរឡើងចំពោះតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានីមួយៗ។

តារាងទី១៖ ការចំណាយនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ [ប្រភព៖ CSO's BWG analysis/2023 **លានរៀល**

| ការវិភាជន៍ការចំណាយជាតិ | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| **សរុបរួមនៃការចំណាយរបស់ជាតិ** | ២៣.៣៧៥. ១០២,០ | | ២៧.១៦៤.៩៩៦,០ | | ៣៣.៣៣៩.៦៦០,០ | | ៣២.០០៩.៧៤២,០ | | ៣៤.៧០៨.៦៣០,០ | | ៣៩.២០៦.២០៥,០ | |
| **ការចំណាយថ្នាក់ជាតិ** (ដកចេញនូវ៖ ខ្ទង់ថវិកានៃការគាំទ្រចំពោះរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ និង ខ្ទង់ថវិកានៃការផ្ទេរការអប់រំ និងសុខាភិបាល) | ២២.៦៩០.៤២៨,០ | ៩៧,១ | ២៤.៩៦៥.៦៥០,០ | ៩១,៩ | ៣០.០១០.៣៩៧,០ | ៩០,០ | ២៨.៦០៦.៨០៥,០ | ៨៩,៤ | ៣០.៤៣៣.៥៦៨,០ | ៨៧,៧ | ៣៤.១៤៧.៨៩២,៦ | ៨៧,១ |
| **ការចំណាយថ្នាក់ក្រោមជាតិ** | ៦៨៤.៦៧៤,០ | ២,៩ | ២.១៩៩.៦៣៩,០ | ៨,១ | ៣.៣២៩.២៦៣,០ | ១០,០ | ៣.៤០២.៩៣៧,០ | ១០,៦ | ៤.២៧៥.០៦២,០ | ១២,៣ | ៥.០៥៨.៣១២,៤ | ១២,៩ |

**ប្រភព៖** ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងពីឆ្នាំ២០១៨ ដល់២០២៣

តារាងទី២៖ ការចំណាយនៅថ្នាក់ជាតិ និងថ្នាក់រាជធានី/ខេត្ត ស្រុក/ខណ្ឌ ឃុំ/សង្កាត់ [ប្រភព៖ CSO's BWG analysis/2023 **លានរៀល**

| ចំណែកនៃការចំណាយថ្នាក់ក្រោមជាតិ | ឆ្នាំ២០១៨ | | ឆ្នាំ២០១៩ | | ឆ្នាំ២០២០ | | ឆ្នាំ២០២១ | | ឆ្នាំ២០២២ | | ឆ្នាំ២០២៣ | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % | ចំនួន | % |
| **សរុបចំណាយថ្នាក់ក្រោមជាតិ** | ២៣.៣៧៥.១០២,០ | | ២៧.១៦៤.៩៩៦,០ | | ៣៣.៣៣៩.៦៦០,០ | | ៣២.០០៩.៧៤២,០ | | ៣៤.៧០៨.៦៣០,០ | | ៣៩.២០៦.២០៥,០ | |
| ការចំណាយថ្នាក់ខេត្ត/រាជធានី រួមទាំងក្រុង | ១.០៩០.២៣៣,០ | ៤,៦៦ | ១.៤៧៦.៩៤៦,០ | ៥,៤៤ | ២.២៧៨.៦៩១,០ | ៦,៨៣ | ២.២០៣.៥៧៩,០ | ៦,៨៨ | ២.៨៥៩.៦៥២,០ | ៨,២៤ | ៣.៤៣៦.២៥០,០ | ៨,៧៦ |
| ការចំណាយថ្នាក់ក្រុង/ស្រុក/ខណ្ឌ | ១៦០.៤០០,០ | ០,៦៩ | ១៩៨.៨៩០,០ | ០,៧៣ | ២៤៧.២២៨,០ | ០,៧៤ | ៤៨៩.៨១០,០ | ១,៥៣ | ៥៦៨.០៥៣,០ | ១,៦៤ | ៦៤៧.១៣៩,៤ | ១,៦៥ |
| ការចំណាយថ្នាក់ឃុំ/សង្កាត់ | ៤៣៤.០៤១,០ | ១.៨៦ | ៥២៣.៨០០,០ | ១,៩៣ | ៨០៣.៣១៧,០ | ២,៤១ | ៧០៩.៥៤៨,០ | ២,២២ | ៨៤៧.៣៥៧,០ | ២,៤៤ | ៩៧៤.៩២៣,០ | ២,៤៩ |

ប្រភព៖ ច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៣

### អនុសាសន៍ទី ១៖

សូមរាជរដ្ឋាភិបាលកម្ពុជា ធ្វើការពិចារណាអំពីការកាត់បន្ថយការចំណាយទូទៅរបស់រដ្ឋាភិបាលថ្នាក់ជាតិដោយសមហេតុផល និងបង្កើនវិភាជន៍ថវិកាឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ[៦] (SNAs) យ៉ាងហោចណាស់ ២០% នៃការចំណាយជាតិនៅឆ្នាំ២០២៤ និងបង្កើនបន្ថែមដល់៣០% នៅឆ្នាំក្រោយៗទៀត ដោយមានការចែករំលែកសមហេតុផលនៃថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ដល់កម្រិតថ្នាក់ស្រុក/ក្រុង សមតាមមុខងារដែលបានប្រគល់ឱ្យ។

## ៣.២. ការរៀបចំថវិកាថ្នាក់ក្រោមជាតិ និងការចូលរួមពីប្រជាពលរដ្ឋ

នៅប្រទេសកម្ពុជា មានរដ្ឋបាលពីរកម្រិត គឺរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ កំណែទម្រង់ប្រព័ន្ធថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ គឺតម្រូវឱ្យមានការបន្សុីគ្នា និងធ្វើសមាហរណកម្មជាមួយថ្នាក់ជាតិ ទាំងការរៀបចំថវិកា ការគ្រប់គ្រង និងរបាយការណ៍ ហើយកម្រិតទាំងពីរនេះ បាននឹងកំពុងអនុវត្តនៅក្នុងគោលនយោបាយជាតិ និងស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។ ផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ខេត្ត (BSPs) នឹងបន្សុីថវិកា និងកម្មវិធីរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលឆ្លើយតបទៅនឹងវិស័យអាទិភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ "ជាអាទិភាពដែលបានលើកឡើងដោយប្រជាពលរដ្ឋ[៧]" ជាមួយនឹងគោលបំណងតាមវិស័យ និងរួមចំណែកគាំទ្រអាទិភាពជាតិ។

## កាលវិភាគសង្ខេបនៃការបង្កើត និងអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

| កាលវិភាគ | សកម្មភាព |
|---|---|
| ខែមីនា ដល់ខែ ឧសភា | ការរៀបចំផែនការថវិកាយុទ្ធសាស្ត្រ៖<br>• សេចក្តីណែនាំពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (MEF) ដល់គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិ និងផែនការថវិកា យុទ្ធសាស្ត្រទាំងអស់ (SBPs) រួមទាំង គម្រោងពីរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវ ដាក់ជូន MEF ត្រឹមថ្ងៃទី ១៥ ឧសភា។ |
| ខែមិថុនា ដល់ខែកញ្ញា | ការរៀបចំថវិការដ្ឋបាលថ្នាក់ក្រោមជាតិ៖<br>• MEF ចេញសារាចរណែនាំដល់រដ្ឋបាល ថ្នាក់ក្រោមជាតិ ដើម្បីរៀបចំផែនការថវិកា លម្អិត<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំផែនការ ថវិកា ផ្សព្វផ្សាយសេចក្តីព្រាងថវិកាជូន សាធារណៈជន ដើម្បីជាមតិកែលម្អ មិនលើសពីថ្ងៃទី ៣០ ខែមិថុនា<br>• រដ្ឋបាលថ្នាក់ក្រោមជាតិ បានបញ្ចប់ និងដាក់ជូន MEF ១៥ ខែកក្កដា ហើយខែ សីហា MEF អាចធ្វើការត្រួតពិនិត្យផ្នែក ច្បាប់ មុនពេលអនុម័តថវិការបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ។ |
| ខែតុលាដល់ ខែធ្នូ | • ការអនុម័តថវិការដ្ឋបាលថ្នាក់ក្រោមជាតិ៖<br>• ខែតុលា ក្រសួងបញ្ជូនថវិការដ្ឋបាលថ្នាក់ ក្រោមជាតិទៅទីស្តីការគណៈរដ្ឋមន្ត្រី<br>• ខែវិច្ឆិកា ទីស្តីការគណៈរដ្ឋមន្ត្រី បញ្ជូន ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ទៅ ព្រឹទ្ធសភា<br>• ខែធ្នូ ការអនុម័តរបស់ព្រឹទ្ធសភា និងការ ឡាយព្រះហស្តលេខាដោយព្រះមហាក្សត្រ។ |

(ប្រភព៖ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ)

ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ៖ គណនេយ្យភាព និងតម្លាភាពក្នុងការគ្រប់គ្រង ការបែងចែកនិងការអនុវត្ត ថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបកាន់តែប្រសើរឡើងនូវតម្រូវការ និង អាទិភាពនានា ដែលលើកឡើងដោយប្រជាពលរដ្ឋ អាចធានាបានតាមរយៈការពិគ្រោះយោបល់ប្រកបដោយអត្ថន័យតាមរយៈការចូលរួម និងមតិកែលម្អពីប្រជាពលរដ្ឋ ជាពិសេសក្រុមជនងាយរងគ្រោះ ស្ត្រី និងយុវជន ក្នុងការធ្វើផែនការថវិកា ការបែងចែក និងការតាមដានការប្រើប្រាស់ថវិការបស់ក្រុមប្រឹក្សា។

នៅថ្នាក់រដ្ឋបាលឃុំ/សង្កាត់ ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការរៀបចំផែនការថវិកា និងការត្រួតពិនិត្យតាមដានគឺនៅមានកម្រិតនៅឡើយ ហើយការចូលរួមនោះមានកាន់តែទាបនៅថ្នាក់រដ្ឋបាលស្រុក/ក្រុង នេះដោយសារកម្រិតចំណេះដឹង និងការយល់ដឹងអំពីថវិការបស់ក្រុមប្រឹក្សា។ សម្រាប់រដ្ឋបាលថ្នាក់ខេត្ត បើយោងតាមមតិយោបល់ពីសមាជិកសម្ព័ន្ធភាព CPDD មកពី ខេត្តបាត់ដំបង បន្ទាយមានជ័យ កំពង់ចាម កំពង់ធំ សៀមរាប និង ស្វាយរៀង បានលើកឡើងថា ពួកគេត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំស្តីពីផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ខេត្ត។

អង្គការសង្គមស៊ីវិលបានសរសើរចំពោះការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់ លេខាធិការដ្ឋាន គ.ជ.អ.ប។តាមរយៈក្រសួងមហាផ្ទៃ នៅខែមិថុនាឆ្នាំ២០២១ បានចេញសេចក្តីណែនាំលេខ សនណ ០២៥ ស្តីពី "លើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើការរៀបចំផែនការ និងការអនុម័តថវិការដ្ឋបាលឃុំ/សង្កាត់"។ ក្នុងនោះផងដែរ  គោលការណ៍ណែនាំ ផ្សព្វផ្សាយពីសេចក្តីព្រាងផែនការថវិកាឃុំ/សង្កាត់ យ៉ាងហោចណាស់ពីរដង (នៅថ្ងៃទី ១៥ និងថ្ងៃទី៣១ ខែតុលា) សម្រាប់សាធារណៈ/សហគមន៍មានរយៈពេលរហូតដល់ពីរសប្តាហ៍។ សេចក្តីណែនាំ ក៏បានបង្ហាញអំពីវិធីសាស្ត្រជាច្រើន សម្រាប់ការផ្សព្វផ្សាយព័ត៌មានថវិកាឃុំ/សង្កាត់ ជាសាធារណៈ ហើយតម្រូវឱ្យមានវគ្គពិគ្រោះយោបល់ចំនួនមួយដងធ្វើឡើងជាមួយសមាជិកសហគមន៍ចម្រុះ រួមទាំងក្រុមជនងាយរងគ្រោះផងដែរ។ សង្គមស៊ីវិលជាមានសេចក្តីសោមនស្សរីករាយ ដែលដឹងថាគោលការណ៍ណែនាំស្រដៀងគ្នា អំពីការលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងកិច្ចដំណើរការរៀបចំ និងការអនុម័តថវិការដ្ឋបាលស្រុក/ក្រុងស្ថិតក្នុងដំណើរការចងក្រងជាសេចក្តីព្រាងសុំការអនុញ្ញាត។

ក្នុងចំណោមសមាជិកសម្ព័ន្ធភាព CPDD ចំនួន១៤ស្ថាប័នក្នុងខេត្តចំនួន៦ ដូចជាខេត្តបាត់ដំបង, បន្ទាយមានជ័យ, កំពង់ចាម, កំពង់ធំ, សៀមរាប និងខេត្តស្វាយរៀង បានឆ្លើយតបនៅក្នុងវគ្គពិគ្រោះយោបល់ថា ពួកគេមិនទាន់បានដឹងពីគោលការណ៍ណែនាំនេះឬមិនទាន់បានចូលរួមក្នុងការអនុវត្តគោលការណ៍ណែនាំទាំងនេះទេ។ ពួកគេបានបន្ថែមទៀតថា ការចូលរួមឬអនុវត្តគឺនៅមានកម្រិត ឬនៅក្នុងតំបន់ខ្លះមិនមានអង្គការសង្គមស៊ីវិល/CBOs ចូលរួមក្នុងការរៀបចំផែនការថវិកានៅកម្រិតរដ្ឋបាលស្រុក/ក្រុង ទោះបីជាបាន

ចូលរួម ឬត្រូវបានអញ្ជើញឱ្យចូលរួមក្នុងសិក្ខាសាលា សមាហរណកម្មស្រុក ក៏ដោយ។ សមាជិកសម្ព័ន្ធភាព CPDD ភាគច្រើនបានអះអាងថា ចំណេះដឹងពួកគេនៅមានកម្រិត លើដំណើរការរៀបចំផែនការថវិកាថ្នាក់រដ្ឋបាលស្រុក/ក្រុង ផងដែរ។ ទោះយ៉ាងនេះក្ដី អង្គការសង្គមស៊ីវិល និងអង្គការ ក្រៅរដ្ឋាភិបាល មានឱកាសបានចូលរួមដើរតួជារដ្ឋបាល ថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ ដើម្បីធានាថាការសម្រេច ចិត្តលើថវិកាមិនត្រឹមតែស្របតាមគោលនយោបាយជាតិ ប៉ុណ្ណោះទេ ប៉ុន្តែត្រូវឆ្លើយតបចំពោះតម្រូវការប្រជាពលរដ្ឋ នៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិផង ដែរ[៩]។

**អនុសាសន៍ទី២៖**

អង្គការសង្គមស៊ីវិលទទួលស្គាល់ការ "បើកចំហ" នៅថ្នាក់ក្រោមជាតិ សម្រាប់ការចូលរួមក្នុងដំណើរការរៀបចំថវិកា របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ អង្គការសង្គមស៊ីវិលសំណូមពរឱ្យមានការចាត់តំណាងរបស់ខ្លួនចូលរួមក្នុងក្រុមការងារ បច្ចេកទេសថវិកាថ្នាក់ជាតិ ដើម្បីឱ្យមានធាតុចូលពីអង្គការសង្គមស៊ីវិលជាសមូហភាព បំណងបង្កើនការសម្រេចចិត្ត នៅថ្នាក់ជាតិក្នុងការវិភាជន៍ថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិបានប្រសើរឡើង។

**អនុសាសន៍ទី៣៖**

តម្រូវការជាបន្ទាន់ បង្កើនចំណេះដឹងផ្នែកថវិការបស់អង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាលដើម្បីឱ្យ ពួកគេអាចបន្តកសាងចំណេះដឹងថវិកា និងការចូលរួមរបស់ប្រជាពលរដ្ឋ/តំណាងសហគមន៍ ក្នុងការរៀបចំថវិកា រដ្ឋបាលថ្នាក់ក្រោមជាតិ ដំណើរការអនុវត្ត និងតាមដាន។ អង្គការសង្គមស៊ីវិលជាតិឈានមុខគេអាចដឹកនាំ ឬដើរ តួនាទីសម្របសម្រួល។

**អនុសាសន៍ទី៤៖**

ការចូលរួមរបស់អង្គការសហគមន៍មូលដ្ឋាន(CBO)/ប្រជាពលរដ្ឋក្នុងការរៀបចំថវិកានៅថ្នាក់ក្រុង/ស្រុក (ឧ. ផ្ដល់ យោបល់ដល់ការរៀបចំថវិកា) នៅមានកម្រិត ឬគ្មាននៅថ្នាក់ក្រុង/ស្រុក ដូច្នេះហើយសង្គមស៊ីវិល/អង្គការមិនមែន រដ្ឋាភិបាលដែលធ្វើការនៅថ្នាក់ក្រុង/ស្រុកគោលដៅ ត្រូវដើរតួនាទីជាស្ពានដើម្បីបង្កើនប្រសិទ្ធភាព តម្លាភាព និង គណនេយ្យភាព នៃដំណើរការរៀបចំថវិកានៅថ្នាក់ក្រុង/ស្រុក។ តម្រូវឱ្យមានការយកចិត្តទុកខ្លាំងឡើងពីរដ្ឋបាលក្រុង/ ស្រុក ចុះជួបអង្គការសង្គមស៊ីវិលធ្វើការក្នុងដែនសមត្ថកិច្ចរបស់ខ្លួនដើម្បីឱ្យមានសហប្រតិបត្តិការភាពជាដៃគូគាំទ្រ បំពេញបន្ថែម។

**អនុសាសន៍ទី៥៖**

លេខាធិការដ្ឋាន គ.ជ.អ.ប ដឹកនាំ[៩] រៀបចំកិច្ចសន្ទនាប្រចាំឆ្នាំរវាងអង្គការសង្គមស៊ីវិល/អ្នកពាក់ព័ន្ធសំខាន់ៗ និង រដ្ឋាភិបាល ដើម្បីដាក់បញ្ចូលធាតុចូលចំពោះដំណើររៀបចំ និងបែងចែកថវិកាដល់រដ្ឋបាលថ្នាក់ក្រោមជាតិ (កិច្ចពិភាក្សាប្រចាំឆ្នាំគួរតែធ្វើឡើង និងស្របតាមកិច្ចប្រជុំគោលនយោបាយថវិកានៅចន្លោះខែមីនា-ឧសភា)។

**អនុសាសន៍ទី៦៖**

រដ្ឋបាលខេត្តរៀបចំវេទិកាពិគ្រោះយោបល់ថវិកាស្រដៀងគ្នាជាមួយអង្គការសង្គមស៊ីវិល/សហគមន៍ និងអ្នកពាក់ព័ន្ធ សំខាន់ៗដើម្បីកំណត់ និងឯកភាពលើធាតុចូលជាសមូហភាព ដើម្បីដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថវិកាខេត្ត ដែលដំណើរការនៅចន្លោះខែមីនាដល់ខែមិថុនា។

**អនុសាសន៍ទី៧៖**

ចំណេះដឹងផ្នែកថវិការបស់ប្រជាពលរដ្ឋនៅមានកម្រិត។ ដូចនេះ សូមជូនជាអនុសាសន៍ចំពោះរដ្ឋបាលឃុំ/សង្កាត់ សូមភ្ជាប់ទំនាក់ទំនងការចូលរួមពីអង្គការសង្គមស៊ីវិល សហគមន៍ និងប្រជាពលរដ្ឋឱ្យបានសកម្មក្នុងការរៀបចំ និងបែងចែកថវិកាឃុំ/សង្កាត់ រួមបញ្ចូលទាំងការ "បង្កើតចំណេះដឹងផ្នែកថវិការបស់ប្រជាពលរដ្ឋ យល់ពីសិទ្ធិ និងតួនាទី និងនីតិវិធីនៃការចូលរួម និងតាមដានការអនុវត្តថវិការបស់រដ្ឋបាលឃុំ/សង្កាត់" ។

**អនុសាសន៍ទី៨៖**

សូមរដ្ឋបាលថ្នាក់ជាតិពន្លឿនការចងក្រង និងការអនុម័តលើគោលការណ៍ណែនាំ សនណ ស្តីពី "ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងការរៀបចំ និងការអនុម័តថវិកា រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ" ដែលបច្ចុប្បន្នកំពុងដំណើរការចងក្រង។

## ៣.៣. តម្លាភាព/ ការទទួលបានព័ត៌មាន "ការកសាងទំនុកចិត្ត"

មានបទប្បញ្ញត្តិមួយចំនួន ដែលស្ថិតក្រោមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ[១០] និងសេចក្តីណែនាំពាក់ព័ន្ធដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ ធ្វើការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរៀងៗខ្លួន។ ប្រជាពលរដ្ឋត្រូវចូលរួមក្នុងការធ្វើសេចក្តីសម្រេចចិត្តក្នុងរយៈពេលចន្លោះការចូលរួមបោះឆ្នោត ជាពិសេសនៅថ្នាក់ក្រោមជាតិ ដើម្បីឱ្យតម្រូវការ និងអាទិភាពនានារបស់ពួកគេ ត្រូវបានឆ្លើយតបកាន់តែប្រសើរឡើងដោយក្រុមប្រឹក្សាជាប់ឆ្នោត និងរដ្ឋបាលគ្រប់គ្រងរបស់ពួកគេ។ ការចូលរួមប្រកបដោយអត្ថន័យ និងការតាមដានពីប្រជាពលរដ្ឋ ក៏ជាការរួមចំណែកដល់ការសម្រេចចិត្តប្រកបដោយតម្លាភាព និងប្រើប្រាស់ថវិកាសាធារណៈប្រកបដោយប្រសិទ្ធភាព។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវខិតខំប្រឹងប្រែង ដើម្បីធានាថាប្រជាពលរដ្ឋអាចទទួលបានព័ត៌មាន "ដោយមានឬគ្មានការទាមទារ"។ កិច្ចខិតខំប្រឹងប្រែងបើកចំហព័ត៌មានរួមមានរបៀបវារៈនៃក្រុមប្រឹក្សា កំណត់ហេតុកិច្ចប្រជុំ ដីកា ថវិកា ការផ្សព្វផ្សាយថវិកា ការសម្រេចចិត្ត ការចំណាយ និងរបាយការណ៍ពាក់ព័ន្ធ។ រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវស្វែងរកមធ្យោបាយផ្សេងៗ ដើម្បីធានាថាការផ្សព្វផ្សាយព័ត៌មានត្រូវបានទៅដល់ប្រជាពលរដ្ឋ និងងាយយល់។

យោងតាមសមាជិកទាំង១៤ស្ថាប័ន របស់សម្ព័ន្ធភាពCPDD ដែលបានពិគ្រោះយោបល់មកពីខេត្តទាំង៦ (ខាងលើ) បានអះអាងថា រដ្ឋបាលស្រុក/ក្រុង មួយចំនួនបានខិតខំប្រឹងប្រែងដើម្បីធ្វើការផ្សព្វផ្សាយ ឬបង្ហាញព័ត៌មានដល់សាធារណៈជនដោយប្រើវិធីសាស្ត្រផ្សេងៗគ្នា (ឧទាហរណ៍ ក្រុងបាត់ដំបង និងក្រុងកំពង់ចាម) និងរដ្ឋបាលស្រុក/ក្រុងជាច្រើនទៀត ប្រើតែផ្ទាំងព័ត៌មាន នៅការិយាល័យស្រុក/ក្រុងតែប៉ុណ្ណោះ។ នៅក្នុងតំបន់មួយចំនួនរដ្ឋបាលស្រុក/ក្រុងនៅមានកម្រិតក្នុងការស្វែងរកមធ្យោបាយផ្សេងៗដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មានដល់ប្រជាពលរដ្ឋ ហើយនេះអាចដោយសារកម្រិតចាប់អារម្មណ៍របស់ប្រជាពលរដ្ឋ[១១] (ការសិក្សាស៊ីជម្រៅ/ការស្ទង់មតិ អាចត្រូវធ្វើឡើងដើម្បីស្វែងយល់ពីហេតុផល)។ ហើយនៅពេលដែលមិនមានការចាប់អារម្មណ៍ គ្មានការទាមទារពីសាធារណជន ហើយមិនអាចទាមទារឱ្យរដ្ឋបាលស្រុក/ក្រុងនោះអាចធ្វើឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិគ្មានទឹកចិត្តព្យាយាមឱ្យអស់ពីសមត្ថភាព។ ការសន្មតផ្សេងទៀតបានឱ្យដឹងថា ទាំងនេះអាចជាការមិនមានជំនឿរវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋ ឧទាហរណ៍ សន្យាច្រើនដង មិនធ្វើសកម្មភាព ឬការអនុវត្តសកម្មភាពមិនឆ្លើយតបទៅនឹងតម្រូវការប្រចាំថ្ងៃរបស់ពួកគេ។ គេជឿថា នៅពេលដែលប្រជាពលរដ្ឋទទួលបានព័ត៌មានពាក់ព័ន្ធ ដែលមានប្រយោជន៍ដល់ជីវិតប្រចាំថ្ងៃរបស់ពួកគេ ឧទាហរណ៍ នៅពេលដែលដឹងថាការសម្រេចចិត្តថវិកាអាចមានប្រយោជន៍ដល់សេវាសុខភាពក្នុងសហគមន៍របស់ពួកគេ "គុណភាពកាន់តែប្រសើរ និងថ្លៃសេវាមានតម្លាភាព" ឬដោះស្រាយអំពីគុណភាពសេវាអប់រំនៅបឋមសិក្សា នៃសាលារៀនដែលកូនរបស់ពួកគេកំពុងចូលរៀន ពួកគេ "អ្នកភូមិ" នឹងចង់ដឹងបន្ថែម ឬហ៊ាននិយាយលើការសម្រេចចិត្តលើថវិការួមជាមួយនឹងចំណេះដឹង និងការ

ចំណាយអំពីថវិកា នឹងបង្កើនផលប្រយោជន៍ ឬបំណងចង់តាមដានការប្រើប្រាស់ថវិកាសាធារណៈពាក់ព័ន្ធ និងការសន្យា ហើយនៅពេលដែលវាកើតឡើង វានឹងធ្វើឱ្យប្រសិទ្ធភាពបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ រួមចំណែកឱ្យមានតម្លាភាព គណនេយ្យភាព និងការឆ្លើយតបកាន់តែច្រើនឡើង និងសេវាសាធារណៈប្រកបដោយសមធម៌។

ដំណោះស្រាយដ៏មានសក្តានុពល ក្នុងការកសាងទំនុកចិត្តពីប្រជាពលរដ្ឋលើរដ្ឋបាលថ្នាក់ក្រោមជាតិ អាចភ្ជាប់ទៅនឹងការបង្ហាញអំពីលទ្ធផល (ឬសកម្មភាព) នៃការផ្តល់សេវាប្រកបដោយប្រសិទ្ធភាព តម្លាភាព និងមានគណនេយ្យភាព រួមទាំងការរក្សាទំនាក់ទំនងទៅវិញទៅមក រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាមួយប្រជាពលរដ្ឋ នឹងគុណភាពនៃព័ត៌មានដែលទទួលបាន (ឧ.ព័ត៌មានដែលភ្ជាប់ទៅនឹងផលប្រយោជន៍ប្រជាពលរដ្ឋ) បង្ហាញជាសាធារណៈ "ដោយមាន ឬគ្មានទាមទារការសួរនាំ"។ ជាថ្មីម្តងទៀត អង្គការសង្គមស៊ីវិលអាចជាស្ពានសម្របសម្រួល ជាដៃគូស្មោះត្រង់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីទទួលបានការជឿទុកចិត្តពីប្រជាពលរដ្ឋ ដូចមានបទពិសោធន៍គួរឱ្យកត់សម្គាល់ខ្លះៗនៅក្រោមសកម្មភាព ISAF នៅក្នុងឃុំគោលដៅមួយចំនួនដែលបានអនុវត្តរួចហើយ។

**អនុសាសន៍ទី៩៖**

រដ្ឋបាលស្រុក/ក្រុង និងអង្គការសង្គមស៊ីវិលខិតខំប្រឹងប្រែងរួមគ្នា ដើម្បីលើកកម្ពស់ការបើកចំហផ្សព្វផ្សាយព័ត៌មាននៃរដ្ឋបាលស្រុក/ក្រុង និងរដ្ឋបាលឃុំ/សង្កាត់ (ជាពិសេសលើការធ្វើសេចក្តីសម្រេចចិត្ត និងថវិកា) តាមរយៈវិធីសាស្ត្រផ្សេងៗ (ឧទាហរណ៍មួយចំនួនត្រូវបានណែនាំនៅក្នុងសេចក្តីណែនាំលេខ០២៥ របស់ក្រសួងមហាផ្ទៃ) ដើម្បីផ្សព្វផ្សាយព័ត៌មានជាសាធារណៈ។ ផ្តល់ធនធានថវិកាសម្រាប់ធ្វើការសាកល្បងកិច្ចខិតខំប្រឹងប្រែងនៃភាពជាដៃគូផ្សេងៗគ្នាហើយប្រសិនបើជោគជ័យ ពង្រីកបទពិសោធន៍ និងការអនុវត្តទៅរដ្ឋបាលថ្នាក់ស្រុក/ក្រុង ឃុំ/សង្កាត់ផ្សេងទៀត។

## ៣.៤. បញ្ហាប្រឈមក្នុងការអនុវត្តថវិការដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់សេវាសង្គម

ការលើកកម្ពស់គុណភាពជីវិតប្រជាពលរដ្ឋ គឺជាការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាជាប់ឆ្នោត និងរដ្ឋបាលថ្នាក់ក្រោមជាតិ។ ពលរដ្ឋដែលចូលរួមអនុវត្តផែនការ និងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ មិនត្រឹមតែអាចដោះស្រាយបញ្ហាគម្រោងហេដ្ឋារចនាសម្ព័ន្ធប៉ុណ្ណោះទេ ប៉ុន្តែអាចដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ច ហើយកិច្ចខិតខំប្រឹងប្រែងនេះនឹងរួមដោះស្រាយបញ្ហាអន្តរវិស័យជាច្រើនដូចជា សមភាពយេនឌ័រ សមភាពសង្គម និងបរិយាបន្ន ដែលមិនអាចរំលងបានឡើយ។

នៅក្នុងកិច្ចសន្ទនាពហុភាគី ស្តីពីការបែងចែកថវិកាជាតិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ នៅសណ្ឋាគារកាំបូឌីយ៉ាណា នៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ក្រោមជំនួយឧបត្ថម្ភពីស្ថានទូតជប៉ុនប្រចាំនៅប្រទេសកម្ពុជា តាមរយៈកម្មវិធីអភិវឌ្ឍរបស់អង្គការសហប្រជាជាតិនៅកម្ពុជា និងសម្របសម្រួលរៀបចំដោយអង្គការសម្ព័ន្ធភាព CPDD ក្រោមអធិបតីភាពតំណាងមកពីលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានអ្នកចូលរួមពីភាគីពាក់ព័ន្ធជាង១០០នាក់ រួមទាំងអ្នកចូលរួមដោយផ្ទាល់ និងចូលរួមពីចម្ងាយ ។ សិក្ខាសាលានេះ បានទទួលស្គាល់ថា ការអនុវត្តគម្រោងសង្គមនៅកម្រិតថ្នាក់ស្រុក/ក្រុង និងកម្រិតថ្នាក់ឃុំ/សង្កាត់ នៅតែប្រឈមនឹងបញ្ហាផ្សេងៗគ្នា រួមទាំងនីតិវិធីមិនច្បាស់លាស់នៃការអនុវត្តថវិកា (ឧ. បញ្ហាលេខកូដសំគាល់ថវិកា ដែលជះឥទ្ធិពលដល់បុរេប្រទាន និងការពន្យារពេលទូទាត់) សម្រាប់ប្រភេទផ្សេងៗនៃសេវាសង្គម លទ្ធកម្មសេវាសង្គមដ៏ស្មុគស្មាញ និងការលើកទឹកចិត្តតិចតួចសម្រាប់ក្រុមប្រឹក្សា ដើម្បីកំណត់អាទិភាពលើការចំណាយសង្គមសម្រាប់ក្រុមអ្នកក្រីក្រ និងជនងាយរងគ្រោះ។

សិក្ខាសាលានេះ ក៏បានទទួលស្គាល់ផងដែរថា មានការខិតខំប្រឹងប្រែងរបស់ក្រសួងមហាផ្ទៃ ដោយមានការគាំទ្រពីអង្គការយូនីសេហ្វ (UNICEF) ដើម្បីដោះស្រាយការអនុវត្តថវិកាសម្រាប់សេវាសង្គម ប៉ុន្តែនៅតែមានបញ្ហាប្រឈមកើត

ឡើងលើការអនុវត្តថវិកាសង្គមនៅកម្រិតមូលដ្ឋាន ដែលទាមទារឱ្យមានការតាមដានបន្ថែមទៀត ដើម្បីធ្វើការដោះស្រាយបញ្ហាដែលបានកើតឡើងទាំងនោះ។

សិក្ខាសាលាក៏ទទួលស្គាល់ដែរថា វាជាឱកាសភាពជាដៃគូផងដែរ (ឧ. ជំរុញការគាំទ្របច្ចេកទេសចម្រុះសម្រាប់សេវាសង្គមប្រកបដោយគុណភាព ការចូលរួមរបស់ប្រជាពលរដ្ឋ និងការតាមដានថវិកា) រវាងរដ្ឋបាលថ្នាក់ក្រោមជាតិ អង្គការសង្គមស៊ីវិល និងវិស័យឯកជន ដើម្បីពង្រឹងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងការឆ្លើយតបទៅនឹងតម្រូវការសង្គម ជាពិសេសចំពោះក្រុមជនក្រីក្រ និងជនងាយរងគ្រោះ ដែលមានប្រវត្តិ ជំនឿវប្បធម៌ ឬនយោបាយផ្សេងៗគ្នា ដើម្បីទទួលបានអត្ថប្រយោជន៍ពីសេវាសង្គមដោយគ្មានការរើសអើង។

**អនុសាសន៍ទី១០៖**

លទ្ធកម្មសេវាសង្គម និងសេចក្ដីណែនាំពាក់ព័ន្ធអំពីការអនុវត្តថវិកាគួរតែត្រូវបានពិនិត្យ និងបកស្រាយបំភ្លឺដើម្បីដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្ន[១២] មានដូចជាសិទ្ធិអំណាច និងភាពបត់បែននៃរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីបន្តអនុវត្តន៍គម្រោងសង្គមនានាប្រកបដោយតម្លាភាព និងគណនេយ្យភាព។

**អនុសាសន៍ទី១១៖**

អង្គការសង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល ស្វែងរកកិច្ចព្រមព្រៀងជាមួយរដ្ឋបាលស្រុក/ក្រុង ដើម្បីចេញដីកា បង្កើត និងសាកល្បងអង្គភាពឆ្លើយតបយេនឌ័រ និងថវិកាសង្គម[១៣] ដើម្បីលើកកម្ពស់ការសម្រេចចិត្តដោយយកចិត្តទុកដាក់ខ្ពស់លើការបែងចែកថវិកាគាំទ្រដោះស្រាយបញ្ហាយេនឌ័រ និងសមធម៌សង្គម។

## END NOTES

[១]. NP-2/ ទំព័រ១៣ សកម្មភាពអាទិភាព ១.៥.៤ ការលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងដំណើរការអភិវឌ្ឍន៍គោលនយោបាយ

[២]. NP-2/ សមាសភាគទី១៖ កំណែទម្រង់ភាពជាអ្នកដឹកនាំ និងការសម្របសម្រួល /ទំព័រ១៣

[3] NP-2/សាររបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន/វិច្ឆិកា ឆ្នាំ២០២១

[៤] ធាតុចូលរបស់ក្រុមការងារថវិការបស់អង្គការសង្គមស៊ីវិល (BWG) លើការវិភាគនៃការបែងចែកថវិកាជាតិឆ្នាំ២០២៣

[៥] BWG និង Tariq H. Niazi, កំណែទម្រង់វិសហមជ្ឈការ និងវិមជ្ឈការនៅកម្ពុជា អនុសាសន៍សម្រាប់ក្របខ័ណ្ឌស្ថាប័ន ទំព័រ៧១ ឆ្នាំ២០១១ ធនាគារអភិវឌ្ឍអាស៊ី

[៦] កម្មវិធីជាតិ (NP-2)/ទំព័រ១៖ រដ្ឋបាលថ្នាក់ក្រោមជាតិ នឹងត្រូវបានផ្តល់ជូនធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ ដែលអាចរកបានតាមរយៈការបង្កើនប្រាក់ចំណូលក្នុងស្រុក និងការផ្ទេរបន្ថែមពីថ្នាក់ជាតិ។

[៧] មាត្រា ២២ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ "រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវគ្រប់គ្រង និងប្រើប្រាស់ថវិការបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងរាជរដ្ឋាភិបាល"

[៨] ច្បាប់ស្តីពីរបបហិរញ្ញវត្ថុសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ/មាត្រា៦ "ក្រុមប្រឹក្សាត្រូវគ្រប់គ្រងកិច្ចការហិរញ្ញវត្ថុសាធារណៈរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួន និងសម្រាប់រាជរដ្ឋាភិបាល..."

[៩] លេខាធិការដ្ឋាននៃ CPDD អាចជាសហអ្នកដឹកនាំដ៏មានសក្តានុពលក្នុងការកៀរគរអង្គការសង្គមស៊ីវិលពាក់ព័ន្ធ និង CBOs ថ្នាក់មូលដ្ឋាន ដើម្បីចូលរួមក្នុងកិច្ចសន្ទនាថ្នាក់ជាតិ។

[១០] ច្បាប់ស្តីពីការគ្រប់គ្រងរាជធានី ខេត្ត ក្រុង ស្រុក និងខណ្ឌ៖ មាត្រា ៣៦, ៥១, ៥២, ១៦៩ និងមាត្រា ១៧០។

[១១] ការសិក្សា/ស្ទង់មតិស៊ីជំរៅ គឺត្រូវការជាចាំបាច់ដើម្បីស្វែងយល់ ឬផ្ទៀងផ្ទាត់ហេតុផលនៃមូលហេតុដែលប្រជាពលរដ្ឋចាប់អារម្មណ៍លើព័ត៌មានក្នុងស្រុក។

[១២] ចាំបាច់ត្រូវធ្វើការសិក្សា/ពិគ្រោះយោបល់ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងអ្នកពាក់ព័ន្ធរបស់អង្គការសង្គមស៊ីវិល ដើម្បីសិក្សាជាពិសេសអំពីបញ្ហាប្រឈមក្នុងវិស័យបច្ចុប្បន្ន (ឧ. បញ្ហាកូដថវិកា បុរេថវិកា និងការពន្យារពេលក្នុងការទូទាត់) និងស្វែងរកមតិកែលម្អរបស់ពួកគេដើម្បីជូនដំណឹងអំពីគោលការណ៍ណែនាំគោលនយោបាយដែលបានកែលម្អលើសេវាសង្គម។

[១៣] កម្មវិធីជាតិ២/សមាសភាព៤ /ទំព័រ៥៣ "វិមជ្ឈការសារពើពន្ធ និងការរៀបចំផែនការ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងការលើកកម្ពស់សមភាពយេនឌ័រ សមភាពសង្គម និងបរិយាបន្ន"។

BUILDING CAPACITY FOR CHANGE

អង្គការសម្ព័ន្ធភាពដៃគូដើម្បីការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
Coalition for Partnership in Democratic Development

Building Community Voices

CISA

COWS

C.T.O.D

IDEA

KHEMARA

pact
building local promise.

RS
RACHNA SATREI ORGANIZATION

STAR KAMPUCHEA

Save Vulnerable Cambodians

Village Support Group
Working for a Fairer Society

UNDP

From
the People of Japan